# ការទិញលក់ដីធ្លី និងបញ្ហាផុសឡើងក្រោយពេលចាប់ផ្ដើមចុះបញ្ជីដីធ្លី

*គំរោងវិភាគបញ្ហាអភិវឌ្ឍន៍ (ADI) របស់គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) ក្នុងកិច្ចសហការជាមួយ មជ្ឈមណ្ឌលព័ត៌មានដីធ្លី (LIC) នៃវេទិកាអង្គការក្រៅរដ្ឋាភិបាលស្ដីពីកម្ពុជា បានធ្វើអង្កេតពីការទិញលក់ដី និងបញ្ហាផុសឡើងតាំងពីពេលចាប់ផ្ដើមចុះបញ្ជីដីធ្លីនៅសង្កាត់ចំនួនពីរនៃខ័ណ្ឌព្រៃនប់ ក្រុងព្រះសីហនុ**

## សេចក្ដីផ្ដើម

ក្រោយពីការអនុមតិច្បាប់ភូមិបាលនៅឆ្នាំ២០០១ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានផ្ដួចផ្ដើមអនុវត្ត គំរោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី (LMAP) នៅឆ្នាំ២០០២ ។ LMAP មានបំណងអភិវឌ្ឍសុវត្ថិភាពប័ណ្ណកម្មសិទ្ធិដី ពង្រឹងប្រព័ន្ធរដ្ឋបាលដីធ្លី និងជំរុញការអភិវឌ្ឍទីផ្សារដីធ្លីអោយកាន់តែមានប្រសិទ្ធភាព ។ ក្រោមការឧបត្ថម្ភពីធនាគារពិភពលោក GTZ (ទីភ្នាក់ងារអាល្លឺម៉ង់សំរាប់កិច្ចសហប្រតិបត្តិការបច្ចេកវិទ្យា) និង FINNMAP (ក្រុមហ៊ុនឯកជនហ្វាំងឡង់ ដែលរដ្ឋាភិបាលហ្វាំងឡង់បានចុះកិច្ចសន្យាជួល) LMAP បានជួយទ្រទ្រង់ដល់កម្មវិធីចុះបញ្ជីដីធ្លីជាប្រព័ន្ធ ដើម្បីចូលរួមកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ។ នៅខែកញ្ញា ឆ្នាំ២០០៧ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រាយការណ៍ថា បានចេញរួចហើយនូវប័ណ្ណកម្មសិទ្ធិដីចំនួន ១លានប័ណ្ណ តាមរយៈ LMAP ។[១] អត្ថបទនេះពិនិត្យពីការទិញលក់ដី និងបញ្ហាផុសឡើងក្រោយពេលចាប់ផ្ដើមចុះបញ្ជីដីធ្លីក្នុងសង្កាត់[២] ចំនួនពីរនៃខ័ណ្ឌព្រៃនប់ ក្រុងព្រះសីហនុ ជាពិសេសបញ្ហាភាពជាម្ចាស់ដី ការលក់ដី ដំណើរការផ្ទេរកម្មសិទ្ធិដី លទ្ធភាពទទួលបានឥណទាន និងសុវត្ថិភាពកាន់កាប់ដី ។

កម្មវិធីចុះបញ្ជីដីធ្លី ផ្អែកលើការសន្មតថា កម្មសិទ្ធិល្អប្រសើរលើដីធ្លីវាជះឥទ្ធិពលវិជ្ជមានលើការប្រើប្រាស់ និងផលិតភាពនៃទ្រព្យទាំងនោះ ។ គំរោងអង្កេតជាមូលដ្ឋាន LMAP តាមតំបន់ជនបទដែលធ្វើឡើងដោយវិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ-CDRI) ក្នុងឆ្នាំ២០០៤ ផ្អែកលើសម្មតិកម្មសំខាន់ៗមួយចំនួនដូចជា ១) ទីផ្សារដីធ្លី: នៅពេលតំលៃដីកើនឡើង ហើយតំលៃដំណើរការទិញលក់ដីថយចុះ ទីផ្សារដីធ្លីនឹងបង្វែរដីធ្លីទៅរកការប្រើប្រាស់ ដែលមានប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់ ។ ២) រដ្ឋបាលដីធ្លី: ចំនួនភាគរយកាន់តែច្រើននៃប្រតិបត្តិការផ្ទេរដីធ្លីដូចជា ការលក់ និងការបន្តមរតក នឹងដំណើរការតាមរយៈការចុះបញ្ជីជាផ្លូវការ ។ ៣) លទ្ធភាពទទួលបានឥណទាន: ប្រជាជននឹង ប្រើប័ណ្ណកម្មសិទ្ធិដីសំរាប់ដាក់ធានា ដើម្បីទទួលបានឥណទានពីស្ថាប័នផ្ដល់កំចីផ្លូវការ ។ ៤) វិវាទ: ប័ណ្ណកម្មសិទ្ធិដីមានសុវត្ថិភាព នឹងកាត់បន្ថយករិត និងភាពញឹកញាប់នៃវិវាទដីធ្លី (CDRI 2007) ។ ការស្រាវជ្រាវដែលបានធ្វើឡើងសំរាប់អត្ថបទនេះ ក៏មានការតំរង់ទិសពីក្របខ័ណ្ឌទ្រឹស្ដីជាទូទៅនេះដែរ ។

## វិធីសាស្ត្រស្រាវជ្រាវ

ការចុះស្រាវជ្រាវដល់កន្លែងសំរាប់ការសិក្សានេះ បានធ្វើឡើងនៅខែឧសភា និងខែមិថុនា ២០០៧ នៅសង្កាត់ព្រៃនប់ និងទឹកល្អក់ ក្នុងខ័ណ្ឌព្រៃនប់ ក្រុងព្រះសីហនុ ។ សង្កាត់ព្រៃនប់ស្ថិតនៅតាមដងផ្លូវជាតិលេខ៤ ខាងត្បូងទីប្រជុំជនខ័ណ្ឌព្រៃនប់ តាមផ្លូវទៅក្រុងព្រះសីហនុ ។ សង្កាត់ទឹកល្អក់ ស្ថិតនៅតាមដងផ្លូវជាតិលេខ៣ ខាងកើតទីប្រជុំជនខ័ណ្ឌព្រៃនប់ តាមផ្លូវទៅខេត្តកំពត ។ សង្កាត់ព្រៃនប់ទទួលរងឥទ្ធិពលពីកំណើនសេដ្ឋកិច្ចនៅតាមដងផ្លូវជាតិលេខ៤ ប៉ុន្តែសង្កាត់ទឹកល្អក់ ស្ថិតនៅដាច់ស្រយាលរហូតដល់ពេលមានការជួសជុលផ្លូវជាតិលេខ៣ ក្នុងសហសវត្សរ៍ថ្មីប៉ុណ្ណោះ ។

ការស្រាវជ្រាវនេះ ប្រើវិធីសាស្ត្របែបគុណភាព និងបរិមាណ ហើយបានចុះអង្កេតសរុប ១៣០គ្រួសារ នៅសង្កាត់ព្រៃនប់ ក្នុងភូមិព្រៃនប់២ និងភូមិបត់សិរមាន់ និង ១៣៤គ្រួសារទៀត នៅសង្កាត់ទឹកល្អក់ ក្នុងភូមិទួល និងភូមិកំពង់ស្មាច់តូច ។[៣] អង្កេតមានមុខសញ្ញាបានអនុវត្តលើគ្រួសារណា ដែលថ្មីៗនេះមានដីកសិកម្មមួយឡូតិ៍យ៉ាងតិចត្រូវបានចុះបញ្ជីដោយ LMAP ។ បន្ថែមពីលើបញ្ជីសំណួរ អង្កេតបានធ្វើសំភាសន៍ជាមួយក្រុមស្នូលដែលមានសមាសភាពជាអ្នកភូមិមកពីតំបន់ស្រាវជ្រាវទាំងបួន ជាមួយអ្នកផ្ដល់ព័ត៌មានគន្លឹះដែលជាអ្នកលក់ដី និងអ្នកទិញដីបានជ្រើសរើសមួយចំនួននៅក្នុងភូមិ និងជាមួយបុគ្គលិកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៅភ្នំពេញ និងក្រុងព្រះសីហនុ ។

## កម្មសិទ្ធិក្បាលដីកសិកម្មចុះបញ្ជីដោយ LMAP[៤]

នៅសង្កាត់ព្រៃនប់ ៩១% នៃក្បាលដីកសិកម្មទាំងអស់ដែលកាន់កាប់ដោយគ្រួសារធ្វើអង្កេត បានទទួលប័ណ្ណកម្មសិទ្ធិពី LMAP រីឯនៅសង្កាត់ទឹកល្អក់គឺមាន ៩៣% ។ ដោយអ្នកកាន់កាប់ដីធំៗក្នុងសង្កាត់ទាំងពីរ មានកាន់កាន់ដីកសិកម្មច្រើនលើសលុប ដូច្នេះ ពួកគេទទួលប្រយោជន៍ពីការចុះបញ្ជីដីធ្លីបានច្រើនជាងអ្នកកាន់កាប់ដីតូចៗ ។[៥] ឧទាហរណ៍ នៅសង្កាត់ព្រៃនប់ គ្រួសារជាម្ចាស់ដីកសិកម្មចាប់ពីមួយហិកតាឡើងទៅដែលចុះបញ្ជីដោយ LMAP តំណាងឱ្យ ៥៤% នៃគំរូតាង ប៉ុន្តែកាន់កាប់ដល់ទៅ ៨៣% នៃដីធ្លីចុះបញ្ជីដោយ LMAP ។ ដូចគ្នាដែរ គ្រួសារនៅសង្កាត់ព្រៃនប់ ជាម្ចាស់ដីកសិកម្មចាប់ពីពីរហិកតាឡើងទៅដែលចុះបញ្ជីដោយ LMAP តំណាងឱ្យតែ ២០% នៃគំរូតាង ប៉ុន្តែកាន់កាប់ដល់ទៅ ៥៤% នៃដីធ្លីចុះបញ្ជីដោយ LMAP ។ ទន្ទឹមគ្នានេះ បើធៀបចំណាត់ថ្នាក់កាន់កាប់ដីពីដីតិចទៅដីច្រើន គេឃើញថាទាំងចំនួន និងទំហំក្បាលដីកាន់កាប់ដែលចុះបញ្ជីដោយ LMAP នៅសង្កាត់ព្រៃនប់ បានកើនឡើង ។

* អត្ថបទនេះ ផ្អែកលើការសិក្សាធ្វើឡើងនៅពាក់កណ្ដាលឆ្នាំ២០០៧ ដែលជាផ្នែកមួយនៃវគ្គសិក្សាស៊ីជំរៅរបស់ ADI ។ អ្នកស្រាវជ្រាវ បានចូលរួមមានជាអាទិ លោក ដួង វីរ័ត្ន និងអ្នកស្រី ឆាយ ពិដោរ (វបសអ) លោក ស្រេង ភិរម្យ និង ចាន់ សារិន (DPA) លោក ថាវ គឹមសាន និង ទូច សេដ្ឋា (លីកាដូ) លោក ម៉េច សុខន និង ខាន់ ចន្ថារ៉ូ (NGO Forum) លោក នួន បូរិន (LWF) លោក លុយ ប៊ុនថន (SCA) លោក កង សុវណ្ណា (ពន្លឺកុមារ) លោក ហ៊ត សីលា (VI) លោក សេង វក (HRVC) លោក ឡុក វិចិត្រ (CHED) លោក ង៉ៃ រ៉េត (ក្រុមអភិវឌ្ឍន៍ភូមិ) និង លោក សាន ជ័យ (KIND) ។ អ្នកស្រាវជ្រាវជាសមាជិកក្រុម គឺមាន លោក ហៃប សុខាន់ណារ៉ូ និង Megan MacInnes (LIC/NGO Forum) និង លោក គុង សៀកលី, អឿ អ៊ីល, ជុំ ស៊ីរ៉ុម, ឃួន ចាន់ឌ៉ុរ និង John McAndrew (ADI/CCC) ។

*តារាង១ : សង្ខេបដីមានប័ណ្ណ LMAP ដែលបានលក់ (ពីឆ្នាំ២០០៣ ដល់ពាក់កណ្តាលឆ្នាំ២០០៧) សង្កាត់ព្រៃទប់ និង សង្កាត់ទឹកល្អក់ ខែឧសភា-មិថុនា ២០០៧*

| | សង្កាត់ព្រៃទប់ | | សង្កាត់ទឹកល្អក់ | | សរុប |
|---|---|---|---|---|---|
| | ចំនួន | % នៃចំនួនសរុប | ចំនួន | % នៃចំនួនសរុប | ចំនួន |
| ក្បាលដី LMAP បានលក់ | ៣៧ក្បាលដី | ៦៣ | ២២ក្បាលដី | ៣៧ | ៥៩ក្បាលដី |
| ទំហំដី LMAP បានលក់ | ១២,៣៦ហ.ត | ៧៤ | ៤,២៤ហ.ត | ២៦ | ១៦,៦ហ.ត |
| ផ្ទៃមធ្យមនៃដី LMAP បានលក់ | ០,៣៣ហ.ត | | ០,១៩ហ.ត | | ០,២៨ហ.ត |
| គ្រួសារបានលក់ដី LMAP | ២៤គ្រួសារ | ៥៥ | ២០គ្រួសារ | ៤៥ | ៤៤គ្រួសារ |

នៅសង្កាត់ទឹកល្អក់ អ្នកកាន់កាន់ដីធំៗដែលកាន់កាប់ដីកសិកម្មច្រើនលើសលុបដែរ គឺទទួលបានផលប្រយោជន៍ពីការចុះបញ្ជីដីធ្លី ច្រើនជាងអ្នកកាន់កាប់ដីតូចៗ ។ ឧទាហរណ៍ គ្រួសារនៅសង្កាត់ទឹកល្អក់ ជាម្ចាស់ដីកសិកម្មចាប់ពីមួយហិកតាឡើងទៅ ដែលចុះបញ្ជីដោយ LMAP តំណាងឱ្យតែ ៣៨% នៃគំរូតាង ប៉ុន្តែកាន់កាប់ដល់ទៅ ៦៩% នៃដីធ្លីចុះបញ្ជីដោយ LMAP ។ ដូចគ្នាដែរ គ្រួសារនៅសង្កាត់ទឹកល្អក់ ជាម្ចាស់ដីកសិកម្មចាប់ពីពីរហិកតាឡើងទៅ ដែលចុះបញ្ជីដោយ LMAP តំណាងឱ្យតែ ១០% នៃគំរូតាង ប៉ុន្តែកាន់កាប់ដល់ទៅ ៣៣% នៃដីធ្លីចុះបញ្ជីដោយ LMAP ។ ទន្ទឹមគ្នានេះ បើធៀបចំណាត់ថ្នាក់កាន់កាប់ដីពីតិចទៅច្រើន គេឃើញថា ទាំងចំនួន និងទំហំក្បាលដីកាន់កាប់ចុះបញ្ជីដោយ LMAP នៅសង្កាត់ទឹកល្អក់ បានកើនឡើងលើកលែងតែក្នុងមួយករណីប៉ុណ្ណោះ ។

## ការលក់ដីពីឆ្នាំ១៩៨៩ ដល់ពាក់កណ្តាលឆ្នាំ២០០៧

ការលក់ដីរបស់អ្នកឆ្លើយសំភាសន៍ក្នុងសង្កាត់ទាំងពីរ ក្នុងរយៈ៤ឆ្នាំកន្លះក្រោយពេលចាប់អនុវត្តគំរោង LMAP មានច្រើនជាងក្នុងរយៈ ១៤ឆ្នាំមុននោះបូកបញ្ចូលគ្នា ។ ចាប់ពីឆ្នាំ១៩៨៩ (ព្រមទាំងឆ្នាំមុនៗនោះទៀត) រហូតមកដល់ឆ្នាំ២០០២ មានការលក់ ៥៦ក្បាលដី ដោយ ៣៤គ្រួសារ នៅសង្កាត់ព្រៃទប់ និងទឹកល្អក់ ។ ជាការប្រៀបធៀបចាប់ពីការផ្តល់ប័ណ្ណ LMAP នៅឆ្នាំ២០០៣ រហូតមកដល់ពេលស្រាវជ្រាវនាពាក់កណ្តាលឆ្នាំ២០០៧ មានការលក់ ៦៦ក្បាលដី ដោយ ៥១គ្រួសារនៅសង្កាត់ទាំងពីរ ហើយក្រោយមកមានការលក់ ៥៩ក្បាលដីមានប័ណ្ណ LMAP និង ៧ក្បាលដីទៀតគ្មានប័ណ្ណ LMAP ។ កំណើនយ៉ាងខ្លាំងនៃការលក់ដីរបស់អ្នកឆ្លើយសំភាសន៍នៅសង្កាត់ទាំងពីរ អាចមើលឃើញយ៉ាងច្បាស់ក្នុងឆ្នាំ២០០៦ ដែលបង្ហាញថា ទីផ្សារដីធ្លីបានរឹងមាំឡើង និងរីកធំជាខ្លាំង (ក្រាហ្វិក១) ។

ជាសរុប មកដល់ឆ្នាំ២០០៦ ការលក់ដីក្នុងគំរូតាងនៅសង្កាត់ព្រៃទប់មានចំនួនស្មើគ្នា រឺច្រើនជាងក្នុងគំរូតាងនៅសង្កាត់ទឹកល្អក់ លើកលែងតែនៅឆ្នាំ ១៩៩៦ ។ នៅមុនពេលអនុវត្ត LMAP (ពីឆ្នាំ១៩៨៩ ដល់ ២០០២) ៨៦% នៃក្បាលដីបានលក់ទាំងអស់ គឺលក់ដោយអ្នកឆ្លើយសំភាសន៍នៅសង្កាត់ព្រៃទប់ ។ ក្នុងអំឡុងពេល LMAP (ពីឆ្នាំ២០០៣ ដល់ពេលចុះស្រាវជ្រាវនៅពាក់កណ្តាលឆ្នាំ២០០៧) អ្នកឆ្លើយសំភាសន៍នៅសង្កាត់ព្រៃទប់បានលក់ ៦១% នៃក្បាលដីបានលក់សរុប ។ ទោះបីគំលាតដ៏ធំនៃចំនួនលក់ដីរវាងអ្នកឆ្លើយសំភាសន៍នៅសង្កាត់ទាំងពីរបានរួមតូចវិញបន្ទាប់ពីការធ្វើប័ណ្ណ LMAP ក្តី ក៏ទិន្នន័យទាំងនេះ បង្ហាញថា ការលក់ដីនៅតែមានកំរិតខ្ពស់ជាងក្នុងចំណោមអ្នកឆ្លើយសំភាសន៍ក្នុងអំឡុងពេល LMAP នៅសង្កាត់ព្រៃទប់ដដែល ។ គួរកត់សំគាល់ថា អ្នកឆ្លើយសំភាសន៍នៅសង្កាត់ទឹកល្អក់ បានលក់ ៦០% នៃក្បាលដីបានលក់សរុប នៅឆមាសទី១ ឆ្នាំ២០០៧ ។ តួលេខនេះបង្ហាញថា

*ក្រាហ្វិក១ : ក្បាលដីលក់ដោយអ្នកឆ្លើយសំភាសន៍ក្នុងសង្កាត់ព្រៃទប់ និង ទឹកល្អក់ ពីឆ្នាំ១៩៨៩ ដល់ពាក់កណ្តាលឆ្នាំ២០០៧*



ក្នុងឆ្នាំ២០០៧ ការលក់ដីអនុវត្តដោយអ្នកឆ្លើយសំភាសន៍នៅសង្កាត់ទឹកល្អក់ អាចមានច្រើនជាងការលក់ដីរបស់អ្នកឆ្លើយសំភាសន៍នៅសង្កាត់ព្រៃនប់ ។ នៅមុនពេល និងក្រោយពេលអនុវត្ត LMAP អ្នកទិញយកដីដែលលក់ចេញដោយអ្នកឆ្លើយសំភាសន៍នៅសង្កាត់ព្រៃនប់ និងទឹកល្អក់ គឺជាអ្នករស់នៅក្នុងភូមិជាមួយពួកគាត់ ។

## ការលក់ដីមានប័ណ្ណ LMAP ពីឆ្នាំ២០០៣ ដល់ពាក់កណ្តាលឆ្នាំ២០០៧

ចាប់តាំងពីមានការចេញប័ណ្ណកម្មសិទ្ធិនៅឆ្នាំ២០០៣ ១៧% នៃគ្រួសារឆ្លើយសំភាសន៍បានលក់ក្បាលដីមានប័ណ្ណ LMAP ។ ពីឆ្នាំ២០០៣ ដល់ពាក់កណ្តាលឆ្នាំ២០០៧ នៅសង្កាត់ព្រៃនប់មាន ២៤គ្រួសារ រឺ ១៨% នៃគ្រួសារឆ្លើយសំភាសន៍ ដែលបានលក់ដីមានប័ណ្ណ LMAP ប៉ុន្តែនៅសង្កាត់ទឹកល្អក់ មានត្រឹមតែ ២០គ្រួសារ រឺ ១៥% នៃគ្រួសារឆ្លើយសំភាសន៍ប៉ុណ្ណោះ ។ ទោះយ៉ាងណាតួលេខប្រហាក់ប្រហែលគ្នានៃចំនួនគ្រួសារអ្នកលក់ដី ហាក់បដិសេធនូវការពិតជាក់ស្តែងដែលថា អ្នកឆ្លើយសំភាសន៍នៅសង្កាត់ព្រៃនប់ បានលក់ដីមានប័ណ្ណ LMAP ច្រើនជាងអ្នកឆ្លើយសំភាសន៍នៅសង្កាត់ទឹកល្អក់ខ្លាំងណាស់ ទោះគិតជាផ្ទៃដី រឺគិតជាចំនួនក្បាលដីក្តី (តារាង ១) ។

បើធៀបនឹងឆ្នាំ១៩៨៩ ដល់ ២០០២ តំលៃដីក្នុងអំឡុងពេល LMAP (២០០៣ ដល់ ពាក់កណ្តាលឆ្នាំ២០០៧) កើនឡើងខ្លាំងណាស់នៅ ៣ភូមិ ក្នុងចំណោម ៤ភូមិគំរូតាង ។ ក្រោយពេលធ្វើ LMAP តំលៃដីជាមធ្យមក្នុងមួយហិកតា ដែលបានលក់នៅសង្កាត់ព្រៃនប់ ក្នុងភូមិព្រៃនប់២ នឹងភូមិបត់សិរមាន់ កើនឡើង ៣២៣% និង ១៩% ។ ដូចគ្នាដែរ នៅសង្កាត់ទឹកល្អក់ក្នុងភូមិទួល និងភូមិកំពង់ស្មាច់តូច វាកើនឡើង ២៣១៣% និង ៤៤៨% ។ម្យ៉ាងទៀត អ្នកទិញមកពីក្រុងព្រះសីហនុ និងភ្នំពេញ កើនឡើងជាង ៥០% នៅអំឡុងពេល LMAP ។ តាមសំដីរៀបរាប់របស់អ្នកភូមិ អ្នកទិញដែលមកពីក្រៅសង្កាត់ទាំងពីរ ចូលចិត្តទិញក្បាលដីទាំងឡាយណាដែលមានប័ណ្ណ LMAP ។

## ហេតុផលនៃការលក់ដី នៅមុនពេល និងក្រោយពេល LMAP

ហេតុផលធំបំផុតដែលធ្វើអោយគ្រួសារនៅសង្កាត់ព្រៃនប់ និងទឹកល្អក់ លក់ដីធ្លីទាំងមុនពេល និងក្រោយពេលធ្វើ LMAP គឺដើម្បីចំណាយព្យាបាលជំងឺ (ក្រាហ្វិក២) ។ នៅមុនពេលធ្វើ LMAP (១៩៨៩-២០០២) ៤៨% នៃក្បាលដីដែលបានលក់ គឺដើម្បីបានប្រាក់ព្យាបាលជំងឺ ។ ដូចគ្នាដែរ ក្រោយពេលធ្វើ LMAP (២០០៣-ពាក់កណ្តាលឆ្នាំ២០០៧) ៤៦% នៃក្បាលដីដែលបានលក់ គឺដើម្បីបង់ថ្លៃព្យាបាលជំងឺ ។ ចំនួនដងនៃការលក់ដីដើម្បីទិញម្ហូបអាហារ បង្កើតរបររកស៊ីផ្សេងៗ និងសំរាប់បុណ្យទាន (មង្គលការ, បុណ្យសព...) គឺមានប្រហាក់ប្រហែលគ្នាក្នុងអំឡុងពេលទាំងពីរ ។ ផ្ទុយទៅវិញ នៅមុនពេលធ្វើ LMAP អ្នកឆ្លើយសំភាសន៍ភាគច្រើនបានលក់ដីដើម្បីទិញដីនៅកន្លែងផ្សេង ប៉ុន្តែក្រោយពេលធ្វើ LMAP អ្នកឆ្លើយសំភាសន៍ភាគច្រើនបានលក់ដីដើម្បីសងបំណុលគេ ។

## ដំណើរការផ្ទេរដី

អ្នកឆ្លើយសំភាសន៍នៅសង្កាត់ព្រៃនប់ និងទឹកល្អក់ បានផ្ទេរសិទ្ធិកាន់កាប់ និងប័ណ្ណកម្មសិទ្ធិពីម្នាក់ទៅម្នាក់ តាមរយៈសាក្សី និងលិខិតបញ្ជាក់ ដែលឃើញមានប្រើនៅពាសពេញប្រទេសកម្ពុជា ។ នៅពេលខ្លះ ពុំមានការផ្លាស់ប្តូរលិខិតស្នាម រឺឯកសារបញ្ជាក់អ្វីទេ នៅពេលប្រគល់ប្រាក់ព្រមព្រៀងគ្នារវាងគូភាគីដែលជាទូទៅគឺជាសាច់ញាតិ អ្នកជិតខាង រឺ មិត្តភ័ក្តិ ។ គ្មានអ្វីគួរអោយភ្ញាក់ផ្អើលទេ ដែលការលក់ដូរដីធ្លីភាគច្រើននៅមុនពេលធ្វើ LMAP បានធ្វើឡើងតាមរយៈកិច្ចសន្យាលក់ ដោយមានការបញ្ជាក់ពីកំរិតភូមិ រឺឃុំ ។ រឿងចំលែកបន្តិច គឺការធ្វើរបៀបរបបនេះបានបន្តអនុវត្តទៀតនៅក្រោយពេលធ្វើ LMAP ដោយសិទ្ធិកាន់កាប់ដីភាគច្រើនត្រូវបានផ្ទេរនៅត្រឹមកំរិតមូលដ្ឋាន ។ និន្នាការប្រហែលគ្នានេះ ក៏អាចពិនិត្យឃើញច្បាស់ដែរក្នុងការទិញដី (តារាង២) ។

LMAP មានបំណងបង្កើនការប្រើប្រាស់បញ្ជីគោលដីធ្លី ប៉ុន្តែបានវាយតំលៃខុសពីភាពរឹងមាំនៃទំនៀមទំលាប់ក្នុងសង្គម ។ ការអនុវត្តផ្ទេរដីដោយ

*ក្រាហ្វិក២ : មូលហេតុនាំឱ្យអ្នកឆ្លើយសំភាសន៍លក់ដី នៅមុនពេល និង ក្រោយពេលធ្វើ LMAP*



*តារាង២ : ដំណើរការផ្ទេរដីតាមរយៈការទិញ និង លក់ដី សង្កាត់ព្រៃនប់ និង សង្កាត់ទឹកល្អក់ ខែឧសភា-មិថុនា ២០០៧*

| | ក្បាលដីបានលក់មុនធ្វើ LMAP | | ក្បាលដីមានប័ណ្ណ LMAP បានលក់ | | ការទិញក្បាលដី | |
|---|---|---|---|---|---|---|
| ការផ្លាស់ប្តូរឈ្មោះម្ចាស់ | ចំនួន | % | ចំនួន | % | ចំនួន | % |
| ការធ្វើកិច្ចសន្យាលក់ និង លិខិតបញ្ជាក់ថ្នាក់ភូមិ | 13 | 23 | 14 | 24 | 63 | 32 |
| ការធ្វើកិច្ចសន្យាលក់ និង លិខិតបញ្ជាក់ថ្នាក់ឃុំ | 29 | 52 | 32 | 54 | 100 | 51 |
| ការធ្វើកិច្ចសន្យាលក់ និង លិខិតបញ្ជាក់ថ្នាក់ស្រុក | 2 | 4 | --- | --- | --- | --- |
| ការផ្ទេរប័ណ្ណនៅការិយាល័យ LMAP សាលាក្រុងព្រះសីហនុ | --- | --- | 1 | 2 | --- | --- |
| ការធ្វើប័ណ្ណនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម ... ក្រុងភ្នំពេញ | --- | --- | --- | --- | 2 | 1 |
| ផ្សេងៗ | 12 | 21 | 12 | 20 | 29 | 15 |
| | សរុប=៥៦ ក្បាលដី | សរុប=៥៩ ក្បាលដី | សរុប=១៩៤ ក្បាលដី | | | |

មានលិខិតបញ្ជាក់ត្រឹមថ្នាក់ភូមិ និងឃុំ បានចាក់ឫសមាំណាស់ក្នុងសង្កាត់បានសិក្សាទាំងពីរ ។ នៅខែមិថុនា ២០០៧ កំណត់ត្រានៅការិយាល័យ LMAP សាលាក្រុងព្រះសីហនុ បង្ហាញថា ក្រោយពេលអនុវត្ត LMAP ក្នុងខណ្ឌព្រៃនប់ទាំងមូល មានការផ្ទេរតែ ៩ក្បាលដី LMAP ប៉ុណ្ណោះដែលបានកត់ត្រាដោយការិយាល័យក្រុង ហើយឈ្មោះម្ចាស់ថ្មីបានកត់ត្រាស្របច្បាប់លើបញ្ជីគោលដីធ្លី ។ ចំពោះការធ្វើកិច្ចសន្យាលក់ត្រឹមថ្នាក់មូលដ្ឋាននេះ អ្នកឆ្លើយសំភាសន៏ ភាគច្រើនមានហេតុផលថា គ្មានការចាំបាច់អ្វីត្រូវធ្វើវែងឆ្ងាយថែមទៀតទេ ពីព្រោះពួកគេមានការជឿទុកចិត្តគ្នា រីឯហេតុផលចង់គេចវេសពីការបង់ពន្ធ កំរមានលើកឡើងណាស់ ។

## ឥណទាន

ដោយសារគំរូតាងសំរាប់ការសិក្សានេះបានជ្រើសរើសឡើង ដោយមានមុខសញ្ញាជាក់លាក់ ដូច្នេះទាំង ២៦៤គ្រួសារដែលឆ្លើយសំភាសន៏ សុទ្ធតែមានយ៉ាងហោចណាស់ដីមួយក្បាលដែលមានប័ណ្ណ LMAP ។ ដោយមូលហេតុនេះ វាគួរអោយចាប់អារម្មណ៏ខ្លាំងណាស់ ដែលការសិក្សាបានរកឃើញថា ៩៣% នៃគ្រួសារឆ្លើយសំភាសន៏នៅសង្កាត់ព្រៃនប់ និង ៩៤%នៃគ្រួសារឆ្លើយសំភាសន៏នៅសង្កាត់ទឹកល្អក់ មិនដែលយកប័ណ្ណ LMAP ទៅដាក់ធានាដើម្បីខ្ចីប្រាក់ទាល់តែសោះ ។ រឿងនេះងាយយល់ទេ នៅពេលគេដឹងថា កំចីជាក្រុមផ្តល់ដោយស្ថាប័នមីក្រូហិរញ្ញវត្ថុអម្រឹត គឺជាប្រភពប្រាក់កំចីចំបងគេរបស់អ្នកឆ្លើយសំភាសន៏ក្នុងសង្កាត់ទាំងពីរ ។ កំចីជាក្រុមរបស់អម្រឹតតំរូវឱ្យមានការធានាពីក្រុម និងភូមិ មិនមែនការដាក់ធានានូវទ្រព្យរបស់បុគ្គលម្នាក់ៗ ដូចជាប័ណ្ណកម្មសិទ្ធិដីនោះទេ ។

តាមការពិនិត្យឃើញ ទឹកប្រាក់ទទួលបានតាមរយៈកម្មវិធីកំចីជាក្រុមរបស់អម្រឹត គឺមានចំនួនគ្រប់គ្រាន់សំរាប់តំរូវការរបស់គ្រួសារឆ្លើយសំភាសន៏ក្នុងសង្កាត់ទាំងពីរ ។ កំចីជាបុគ្គលម្នាក់ៗពីអម្រឹត និងធនាគារអេស៊ីលីដា ដែលទូទៅមានទឹកប្រាក់ច្រើនៗ និងត្រូវមានវត្ថុដាក់ធានាដូចជាប័ណ្ណ LMAP ជាដើម កំរឃើញមានណាស់ក្នុងចំណោម គ្រួសារបានឆ្លើយសំភាសន៏ ។[១១] ដរាបណាកម្មវិធីកំចីជាក្រុមរបស់អម្រឹត នៅតែបន្តផ្គត់ផ្គង់បានតាមតំរូវការឥណទានរបស់អ្នកខ្ចីប្រាក់ក្នុងភូមិ ដរាបនោះប័ណ្ណកម្មសិទ្ធិដី LMAP នឹងមានតួនាទីតិចតួចប៉ុណ្ណោះក្នុងការបង្កើនលទ្ធបាពទទួលបានឥណទាន រឺ ផ្លាស់ប្តូររបៀបរបបស្វែងរកឥណទាននាបច្ចុប្បន្នរបស់ប្រជាពលរដ្ឋ ។

## សុវត្ថិភាពកាន់កាប់ដី

ជាទូទៅគ្រួសារឆ្លើយសំភាសន៏មានអារម្មណ៏ថា ពួកគេមានសុវត្ថិភាពខ្ពស់ជាងក្នុងការកាន់កាប់ដីកសិកម្មដែលមាន ប័ណ្ណ LMAP បើធៀបនឹងកាលពីមុនដែលមិនទាន់មានប័ណ្ណ ។ អ្នកឆ្លើយសំភាសន៏ដែលប្រាប់បែបនេះ មាន ៩១% នៅសង្កាត់ព្រៃនប់ និង ៩០% នៅសង្កាត់ទឹកល្អក់ ។[១២] ពួកគេបានផ្តល់ហេតុផលជាច្រើនពីអារម្មណ៏មានកំណើនសុវត្ថិភាពនេះ ដូចជា មានឈ្មោះរបស់ខ្លួនលើប័ណ្ណកម្មសិទ្ធិ មានការទទួលស្គាល់ប័ណ្ណកម្មសិទ្ធិក្នុងច្បាប់ភូមិបាល មានហត្ថលេខាមន្ត្រីសុរិយោដីនៅលើប័ណ្ណ និងមានការបញ្ជាក់ពីព្រំប្រទល់ និងវិវាទលើកម្មសិទ្ធិដី ។ ក្នុងចំណោមអ្នកឆ្លើយសំភាសន៏នៅសង្កាត់ទាំងពីរ ដែលមានទាំងដីកសិកម្មមានប័ណ្ណ LMAP និងដីកសិកម្មគ្មានប័ណ្ណ LMAP ៩៧% បានឆ្លើយថា ក្បាលដីមានប័ណ្ណ LMAP មានសុវត្ថិភាពជាង ។

## សេចក្តីសន្និដ្ឋាន

នៅតំបន់សិក្សាក្នុងសង្កាត់ព្រៃនប់ និងទឹកល្អក់ ជាង ៩០% នៃក្បាលដីកសិកម្មទាំងអស់ដែលកាន់កាប់ដោយ គ្រួសារឆ្លើយសំភាសន៏នានា គឺទទួលបានប័ណ្ណពី LMAP ហើយនេះជាជោគជ័យមួយដ៏ធំ ។ ម្យ៉ាងទៀត វិសមភាពកាន់កាប់ដីក្នុងចំណោមអ្នកបានទទួលប័ណ្ណកម្មសិទ្ធិដី មានន័យថា អ្នកកាន់កាប់ដីធំៗនៅសង្កាត់ទាំងពីរដែល មានដីច្រើនលើសលប់ គឺបានទទួលផលប្រយោជន៏ពីការចុះបញ្ជីដីធ្លីច្រើនជាងអ្នកកាន់កាប់ដីតូចៗ ។ ដូច្នេះការផ្តល់ប័ណ្ណកម្មសិទ្ធិតាមគំរោង LMAP បានពង្រីងវិសមភាពកាន់កាប់ដី ព្រមគ្នានឹងការពង្រឹងសិទ្ធិលើទ្រព្យសម្បត្តិសំរាប់ប្រជាពលរដ្ឋគ្រប់រូបដែរ ។

ការលក់ដីនៅសង្កាត់ទាំងពីរ ក្នុងរយៈ៤ឆ្នាំកន្លះ ក្រោយពេលចាប់អនុវត្តគំរោង LMAP មានចំនួនច្រើនជាងក្នុងរយៈ ១៤ឆ្នាំមុននោះរួមគ្នាទាំងអស់ ។ ចំណុចនេះបង្ហាញថា ប័ណ្ណ LMAP បានជួយជំរុញឱ្យទីផ្សារដីធ្លីសកម្មឡើង ។

អ្នកទិញដែលរស់នៅក្នុងភូមិជាមួយអ្នកលក់ នៅតែមានច្រើនជាងគេ ទាំងនៅមុនពេល និងក្រោយពេលអនុវត្ត LMAP ប៉ុន្តែអ្នកទិញមកពីក្រុងព្រះសីហនុ និងក្រុងភ្នំពេញ បានកើនមួយជាពីរក្នុងអំឡុងពេល LMAP ។ ក្រោយការធ្វើប័ណ្ណ LMAP តំលៃដីក៏កើនឡើងខ្ពស់ណាស់ដែរសំរាប់ ៣ភូមិក្នុងចំណោមភូមិសិក្សាទាំង៤ ។ កំណើនតំលៃដីផ្តល់ផលចំណេញដល់អ្នកភូមិដែលលក់ដីក៏ពិតមែន ប៉ុន្តែគ្រួសារនានាតាមធម្មតាមិនមែនលក់ដីដើម្បីធ្វើវិនិយោគបង្កើនផលិតភាពនោះទេ ព្រោះជិត ៥០% នៃក្បាលដីដែលបានលក់ក្រោយពេលធ្វើ LMAP គឺដើម្បីយកប្រាក់ព្យាបាលជំងឺ ។ ដូច្នេះការលក់ដីនៅក្រោយពេលអនុវត្តគំរោង LMAP បានធ្វើឡើងជាសំខាន់ដើម្បីបានប្រាក់ប្រើប្រាស់នៅពេលជួបប្រទះគ្រោះអាសន្ន និងដោះស្រាយតំរូវការចិញ្ចឹមជីវិត ។

ក្រោយពេលធ្វើ LMAP ការលក់ដីភាគច្រើន នៅតែធ្វើឡើងក្រោមកិច្ចសន្យាលក់មានការបញ្ជាក់ពីថ្នាក់ភូមិ និងឃុំ ដោយគ្មានការផ្ទេរសិទ្ធិតាមការចុះបញ្ជីគោលដីធ្លីទេ ។ អ្នកភូមិភាគច្រើនគិតថា គ្មានការចាំបាច់អ្វីត្រូវធ្វើវែងឆ្ងាយថែមទៀតទេ ពីព្រោះពួកគេជឿទុកចិត្តគ្នាទៅវិញទៅមក ហើយជាទូទៅបទពិសោធន៏របស់ពួកគេនេះហុចលទ្ធផលល្អ ។ អ្នកទិញមកពីក្រៅភូមិ តាមធម្មតាមិនទាមទារការផ្ទេរសិទ្ធិតាមការចុះបញ្ជីគោលដីធ្លីថែមទៀតទេ ។ ដូចគ្នាដែរ នៅសង្កាត់ព្រៃនប់ ស្ថាប័នមីក្រូហិរញ្ញវត្ថុអម្រឹត និងធនាគារអេស៊ីលីដា ទទួលយកប័ណ្ណកម្មសិទ្ធិដី LMAP ព្រមជាមួយកិច្ចសន្យាលក់ និងលិខិតញ្ជាក់ធ្វើជាវត្ថុដាក់ធានាសំរាប់ការខ្ចីប្រាក់ ទោះបីជាប័ណ្ណទាំងនោះមិនបានឆ្លងកាត់ ការចុះបញ្ជីគោលដីធ្លីក៏ដោយ ។ ដូចនេះ បើសិនគ្មានការដាក់អនុវត្តតឹងរឹងនូវការតំរូវផ្សេងៗក្នុងច្បាប់ (ដែលប្រហែលជាពុំមានទេ) រីក៏ការផ្លាស់ប្តូរនីតិវិធីសព្វថ្ងៃ របៀបរបបផ្ទេរកម្មសិទ្ធិដី "ក្រៅផ្លូវច្បាប់" នៅតែបន្តអនុវត្តទៀត ហើយនៅទីបំផុតនឹងគំរាមកំហែងដល់ជោគជ័យនៃកម្មវិធីចុះបញ្ជីដីធ្លីជាប្រព័ន្ធតែម្តង ។

ជាង ៩០% នៃគ្រួសារឆ្លើយសំភាសន៏ក្នុងសង្កាត់ទាំងពីរ មិនដែលយកប័ណ្ណកម្មសិទ្ធិដី LMAP ទៅដាក់ធានាដើម្បីសុំខ្ចីប្រាក់ទេ ។ ដរាបណាកម្មវិធីកំចីជាក្រុមរបស់អម្រឹត នៅតែបន្តដោះស្រាយបានតាមតំរូវការឥណទានរបស់អ្នកភូមិ ដរាបនោះប័ណ្ណកម្មសិទ្ធិដីដែលទទួលបានពី LMAP នៅតែមានតួនាទីតិចតួចក្នុងការបង្កើនលទ្ធភាពទទួលបានឥណទាន រឺការផ្លាស់ប្តូររបៀបរបបស្វែងរកឥណទានរបស់អ្នកភូមិនាបច្ចុប្បន្ន ។

ភាគច្រើនលើសលប់នៃគ្រួសារឆ្លើយសំភាសន៏បានប្រាប់ថា ផលប្រយោជន៏ចំបងដែលទទួលបានពី LMAP គឺសុវត្ថិភាពខ្ពស់ជាងមុនក្នុងការកាន់កាប់ដីមានប័ណ្ណកម្មសិទ្ធិ LMAP ។ អ្នកភូមិបានដឹងច្បាស់ពីសំពាធដែលពួកអ្នកទិញលក់ដីកេងយកចំណេញ និងអ្នកអភិវឌ្ឍន៏ដី អាចដាក់មកលើអ្នកភូមិ ហើយការមានប័ណ្ណកម្មសិទ្ធិក្នុងដៃវាផ្តល់ឧត្តមភាពមួយយ៉ាងធំ ។ ពិតមែនតែប័ណ្ណកម្មសិទ្ធិ LMAP មិនអាចជួយកាត់បន្ថយភាពក្រីក្របានភ្លាមៗសំរាប់អ្នកមានប័ណ្ណភាគច្រើនក្តី ក៏ប៉ុន្តែវាជាធាតុផ្សំមួយដ៏សំខាន់នៃកញ្ចប់អន្តរាគមន៏សំរាប់អភិវឌ្ឍន៏និងកំណែទំរង់ ដែលមានដូចជា ការផ្តល់គ្រប់គ្រាន់នូវសេវាថែទាំសុខភាពមានប្រសិទ្ធភាពល្អ និងតំលៃថោកសមរម្យ និងដែលអាចជួយរុញច្រានប្រជាពលរដ្ឋឱ្យចាកផុតពីភាពក្រីក្រ ហើយទទួលផលប្រយោជន៏បានកាន់តែស្មើភាពពីកំណើនសេដ្ឋកិច្ច ។

## កំណត់សំគាល់

១. អត្ថបទនេះប្រើពាក្យ "ប័ណ្ណ LMAP" សំរាប់ប័ណ្ណកម្មសិទ្ធិដីរបស់ខាងសុរិយោដី ដែលចេញឱ្យតាមគំរោង LMAP ។

២. សង្កាត់ គឺជាផ្នែករដ្ឋបាលមួយនៅក្នុងរាជធានី រឺទីក្រុង ដែលស្មើនឹងឃុំនៅតាមខេត្ត ។

៣. បញ្ជីសំនួរអង្កេតផ្អែកលើឧបករណ៏ ដែលបានប្រើក្នុងគំរោងអង្កេតជាមូលដ្ឋានរបស់ វបសអ-CDRI (CDRI 2007) ។

៤. ទិន្នន័យ ក្រាហ្វិក និងតារាង ដែលបង្ហាញជូននៅក្នុងអត្ថបទនេះ បានមកពីគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC)/វេទិកាអង្គការក្រៅរដ្ឋាភិបាលសំរាប់ការសិក្សាពីកម្ពុជា : *ការចុះបញ្ជីដីធ្លី និងការកាត់បន្ថយភាពក្រីក្រ: ការសិក្សានៅសង្កាត់ចំនួនពីរក្នុងខ័ណ្ឌព្រៃនប់ ក្រុងព្រះសីហនុ,* ក្រុមវិភាគបញ្ហាអភិវឌ្ឍន៏ និងអ្នកចូលរួមស្រាវជ្រាវដោយរួមសហការជាមួយមជ្ឈមណ្ឌលព័ត៌មានដីធ្លី នៅខែវិច្ឆិកា ឆ្នាំ២០០៧ ។

៥. អ្នកកាន់កាប់ដីធំៗ ដែលមានដីកសិកម្មច្រើនលើសលុប ទទួលផលប្រយោជន៏ពីការធ្វើប័ណ្ណកម្មសិទ្ធិដី បានច្រើនជាងអ្នកកាន់កាន់ដីតូចៗតាមរយៈតំលៃបន្ថែមបានដល់ទ្រព្យ កំណើនរបស់ដាក់ធានាដើម្បីទទួលបានឥណទានផ្លូវការ និងសុវត្ថិភាពកាន់កាប់ផ្ទៃដីបានកាន់តែធំ ។

៦. ខណៈដែលការលក់ដីក្នុងអំឡុងពេល LMAP (២០០៣-ពាក់កណ្តាលឆ្នាំ២០០៧) មានចំនួនច្រើនជាងក្នុងអំឡុងពេលមុន LMAP (១៩៨៩-២០០២) គេគួរកត់ចំណាំថា ទំហំដីសរុបដែលបានលក់ក្នុងអំឡុងពេល LMAP (២០ហិកតា) វាតិចជាខ្លាំងជាងទំហំដីដែលបានលក់មុនពេល LMAP (៣០ហិកតា) ។

៧. ក្នុងផ្នែកនេះ និងផ្នែកបន្តបន្ទាប់ទៀត ការលើកឡើងពីក្បាលដីបានលក់ពីឆ្នាំ២០០៣ ដល់ ពាក់កណ្តាលឆ្នាំ២០០៧ មានរួមបញ្ចូលតែក្បាលដីមានប័ណ្ណ LMAP ដែលបានលក់ចំនួន ៥៩ក្បាលដីប៉ុណ្ណោះ ។ រីឯ ៧ក្បាលដីគ្មានប័ណ្ណ ដែលបានលក់អំឡុងពេលដូចគ្នា មិនបានគិតបញ្ចូលទេ ។

៨. តំលៃមធ្យមក្នុងមួយហិកតានៃក្បាលដីដែលបានលក់ នៅមុនពេលអនុវត្ត LMAP (១៩៨៩-២០០២) និងក្រោយអនុវត្ត LMAP (២០០៣ ដល់ពាក់កណ្តាលឆ្នាំ២០០៧) បានកើនឡើងនៅភូមិព្រៃនប់២ ពី ៤១៩ដុល្លារ ដល់ ១៧៧១ដុល្លារ ភូមិបត់សិរមាន់ ពី ១៦៣១ដុល្លារ ដល់ ១៩៤០ដុល្លារ ភូមិទួល ពី ២៩២ដុល្លារ ដល់ ៧០៤៧ដុល្លារ និងភូមិកំពង់ស្មាច់តូច ពី ១៦១ដុល្លារ ដល់ ៨៨៣ដុល្លារ ។

៩. CDRI (2004) រាយការណ៏ថា ការថែទាំសុខភាពជាមូលហេតុនាំអោយមានការលក់ក្បាលដីចំនួន ២៥% ក្នុងតំបន់គោលដៅ LMAP ពីឆ្នាំ ១៩៨៩ -២០០៤ ។

១០.ការផ្ទេរសិទ្ធិធ្វើឡើងដោយគ្មានលិខិតស្នាម រឺលិខិតបញ្ជាក់សំរាប់ចំលើយក្នុងខ្ទង់ "ផ្សេងៗ" នៃតារាង២ ។

១១.ទាំងស្ថាប័នមីក្រូហិរញ្ញវត្ថុអម្រឹត និងធនាគារអេស៊ីលីដា មានសាខានៅទីប្រជុំជនខ័ណ្ឌព្រៃនប់ ។

១២.CDRI (2007) រាយការណ៏ថា ៨០% នៃគ្រួសារឆ្លើយសំភាសន៏នៅតំបន់អនុវត្ត LMAP មានអារម្មណ៏ថា សុវត្ថិភាពកាន់កាប់ដី គឺជាផលប្រយោជន៏សំខាន់ជាងគេ ដែលទទួលបានពីការចុះបញ្ជីដីធ្លី ។

## ឯកសារយោង

វបសអ-CDRI (2007), កម្មវិធីចុះបញ្ជីដីធ្លីនៅក្នុងប្រទេសកម្ពុជាៈ របាយការណ៏អង្កេតមូលដ្ឋាននៅតំបន់ជនបទ (ភ្នំពេញ : វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៏កម្ពុជា)